# សេចក្តីថ្លែងការណ៍

## គាំទ្រការបើកចំហព័ត៌មានកិច្ចព្រមព្រៀងក្នុងវិស័យ រ៉ែ ប្រេង និងឧស្ម័ន ជាសាធារណៈ

## អបអរទិវាសិទ្ធិទទួលព័ត៌មាន ២៨ កញ្ញា

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤

នៅប្រទេសកម្ពុជា ការទទួលបានព័ត៌មានពីវិស័យផ្សេងៗនៅមានកម្រិត និងមានការលំបាក ដោយសារសិទ្ធិរបស់ពលរដ្ឋក្នុងការទទួលបានព័ត៌មានទាំងនោះមិនត្រូវបានធានាដោយច្បាប់។ វាកាន់តែលំបាកជាងនេះទៅទៀត នៅពេលដែលពលរដ្ឋចង់ដឹងព័ត៌មានពីវិស័យរ៉ែ ប្រេង និងឧស្ម័ន ដោយព័ត៌មានស្ទើរតែទាំងអស់ ត្រូវបានដាក់ឲ្យស្ថិតក្រោម «ការសម្ងាត់» ដែលបានចែងនៅយ៉ាងជាក់ច្បាស់នៅក្នុងច្បាប់ស្តីពីការគ្រប់គ្រង និងធ្វើអាជីវកម្មធនធានរ៉ែ និងបទបញ្ញត្តិស្តីពីប្រេងកាត។ មានន័យថា រាល់ឯកសារ ទិន្នន័យ របាយការណ៍ ផែនការ រួមទាំងកិច្ចព្រមព្រៀងត្រូវរក្សាទុកជាការសម្ងាត់ លើកលែងតែមានការអនុញ្ញាតិពីសម្បទានិក និងរដ្ឋាភិបាលឲ្យធ្វើការផ្សព្វផ្សាយជាសាធារណៈ។ ក្របខ័ណ្ឌច្បាប់ទាំងនេះបានកម្រិតព័ត៌មានដែលពលរដ្ឋចង់ដឹង និងធ្វើឲ្យការចូលរួមរបស់ពលរដ្ឋមានតិចតួចនៅក្នុងដំណើរការអភិវឌ្ឍន៍វិស័យដ៏មានសក្តានុពលសម្រាប់សេដ្ឋកិច្ចជាតិ ដែលជាហេតុបង្កឲ្យកើតមានទំនាស់ជារឿយៗរវាងសហគមន៍ក្នុងតំបន់ ជាមួយក្រុមហ៊ុនរ៉ែ ទៅលើបញ្ហាដីធ្លី បរិស្ថាន និងប្រពៃណីទំនៀមទម្លាប់ជាដើម។

កង្វះព័ត៌មានកិច្ចព្រមព្រៀងក្នុងវិស័យនេះ ពលរដ្ឋមិនបានដឹងពីខ្លឹមសារដែលរដ្ឋាភិបាលបានព្រមព្រៀងជាមួយក្រុមហ៊ុនរ៉ែ ប្រេង និងឧស្ម័ន ដូចជាការបែងចែកផល, ទីតាំងប្រតិបត្តិជាក់លាក់ និងរយៈពេលនៃកិច្ចព្រមព្រៀង, សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីកិច្ចព្រមព្រៀង, កាតព្វកិច្ចក្នុងការបង់ពន្ធ, កិច្ចការពារបរិស្ថាន, ការផ្តល់ផលប្រយោជន៍ដល់សហគមន៍ក្នុងតំបន់ និងការទូទាត់ថ្លៃដើមរបស់ក្រុមហ៊ុនជាដើម។

ខណៈពេលដែលក្របខ័ណ្ឌច្បាប់វិស័យរ៉ែ ប្រេង និងឧស្ម័ន កំពុងស្ថិតក្នុងដំណើរការតាក់តែង កែលម្អរ និងស្ថិតក្នុងសេចក្តីព្រាងនៅឡើយ ការទាមទារឲ្យដាក់បញ្ចូលល័ក្ខខ័ណ្ឌបើកចំហរជាសាធារណៈនូវកិច្ចព្រមព្រៀងទាំងនេះ គឺជាឱកាសដែលអាចទាញឲ្យវិស័យនេះត្រូវបានគ្រប់គ្រងប្រកបដោយតម្លាភាព និងគណនេយ្យភាព។ មានភស្តុតាងជាច្រើនដែលបង្ហាញឲ្យឃើញថា ការបើកចំហរកិច្ចព្រមព្រៀង អាចនាំឲ្យមានការយល់ដឹងទូលំទូលាយក្នុងចំណោមប្រជាពលរដ្ឋ និងរដ្ឋាភិបាល និងជួយជម្រុញឲ្យមានអភិបាលកិច្ចល្អ សម្រាប់ការគ្រប់គ្រងវិស័យរ៉ែ ប្រេង និងឧស្ម័ន នៅក្នុងប្រទេសកម្ពុជា។ ប្រជាពលរដ្ឋអាចជួយរដ្ឋាភិបាលក្នុងការវិភាគទៅលើកិច្ចព្រមព្រៀង ជួយតាមដានការអនុវត្តរបស់ភាគីកិច្ចព្រមព្រៀងឲ្យកាន់តែមានប្រសិទ្ធិភាព ហើយរដ្ឋាភិបាលអាចមានចំណេះដឹងទូលំទូលាយក្នុងការចរចាសម្រាប់កិច្ចព្រមព្រៀងក្រោយៗទៀត។

ដោយមើលឃើញពីសារៈសំខាន់ខាងលើនេះ សម្ព័ន្ធភាពកម្ពុជាដើម្បីតម្លាភាពចំណូលធនធាន ដែលជាសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលចំនួន ៧ អង្គការ និងសមាជិកគាំទ្រជាង ១០០០នាក់ សូមស្នើដល់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាស្ថាប័ននីតិបញ្ញត្តិ មេត្តាពិនិត្យ និងពិចារណាដាក់បញ្ចូល ល័ក្ខខ័ណ្ឌបើកចំហព័ត៌មានពីកិច្ចព្រមព្រៀងក្នុងវិស័យរ៉ែ ប្រេង និងឧស្ម័នជាសាធារណៈ ទៅក្នុងក្របខ័ណ្ឌច្បាប់ដែលពាក់ព័ន្ធ ដើម្បីឆ្លើយតបទៅនឹងការប្តេជ្ញាចិត្តខ្ពស់របស់រាជរដ្ឋាភិបាលក្នុងគ្រប់គ្រងវិស័យនេះឲ្យមានតម្លាភាព។

<u>សម្ព័ន្ធភាពកម្ពុជាដើម្បីតម្លាភាពចំណូលធនធាន (CRRT) និងអង្គការជាសមាជិក</u>

១. វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API)
២. អង្គការអភិវឌ្ឍន៍ និងភាពជាដៃគូក្នុងសកម្មភាព (DPA)
៣. វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NGO Forum)
៤. អង្គការអនុផលព្រៃឈើ (NTFP)
៥. អង្គការស្តារកម្ពុជា (STAR KAMPUCHEA)
៦.មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM)
៧. អង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន (YRDP)